

# ELECTION 2020

Call:
**1-888-API-VOTE**
(274-8683)

Bilingual assistance is available in English, Mandarin (普通話/普通话), Cantonese (廣東話/广东话), Korean (한국인), Vietnamese (Tiếng Việt), Tagalog, Urdu (اردو), Hindi (हिन्दी), and Bengali (বাংলা).

ASIAN AMERICANS ADVANCING JUSTICE AAJC

# បញ្ហាជំងឺកូវីដ-19 & ការបោះឆ្នោត៖ ការអនុវត្តល្អបំផុតសម្រាប់សុវត្ថិភាព

*(ផ្អែកលើគោលការណ៍ណែនាំរបស់ CDC ស្ដីពី "ការពិចារណាសម្រាប់អ្នកបោះឆ្នោតនិងទីតាំងការិយាល័យបោះឆ្នោត" @ https://www.cdc.gov/coronavirus/2019-ncov/community/election-polling-locations.html)*

អ្នកគួរស្វែងយល់និងពិចារណារកមើលនូវជម្រើសនៃការបោះឆ្នោតដែលមានផ្សេងទៀតនៅក្នុងតំបន់របស់អ្នក ដែលជួយកាត់បន្ថយការធ្វើទំនាក់ទំនងជាអប្បបរមា ដូចជាការបោះឆ្នោតតាមរយៈសំបុត្រប្រៃសណីយ៍។ ទោះជាយ៉ាងណាក្ដី អ្នកមានជម្រើសក្នុងការសម្រេចថាតើវិធីសាស្ត្របោះឆ្នោតណាមួយល្អបំផុតសម្រាប់អ្នក។
ប្រសិនបើអ្នកជ្រើសយកការបោះឆ្នោតដោយផ្ទាល់ សូម្បីក្នុងពេលការបោះឆ្នោតជាមុនថ្ងៃកំណត់ ឬនៅថ្ងៃបោះឆ្នោត សូមអនុវត្តតាមការណែនាំដែលល្អបំផុតទាំងនេះដែលអាចជួយឱ្យអ្នកមានសុវត្ថិភាពក្នុងពេលបោះឆ្នោត។

## ចៀសវាងកន្លែងដែលមានមនុស្សច្រើនកុះករ

- បោះឆ្នោតមុនថ្ងៃកំណត់ ប្រសិនបើមាននៅក្នុងយុត្តាធិការរបស់អ្នក។ [សូមមើល https://www.usvotefoundation.org/vote/state-elections/state-voting-laws-requirements.htm]
- ប្រសិនបើអាច ចូរបោះឆ្នោតនៅពេលដែលពុំមានមនុស្សច្រើន ដូចជានៅពេលពាក់កណ្ដាលព្រឹក។
- ប្រសិនបើអ្នកបើករថយន្តទៅមណ្ឌលបោះឆ្នោតហើយអ្នកមានពេលវេលាគ្រប់គ្រាន់ ចូរពិនិត្យមើលជួរអ្នកបោះឆ្នោតពីរថយន្តរបស់អ្នក ហើយនៅពេលការតម្រង់ជួរខ្លីចាំអ្នកដើរមកចូលរួមនឹងគេ។

## មកកាន់មណ្ឌលបោះឆ្នោតដោយបានត្រៀមខ្លួនជាស្រេច

- ពិនិត្យមើលទីតាំងនិងលក្ខខណ្ឌនៃមណ្ឌលបោះឆ្នោតរបស់អ្នកជាមុន ពីព្រោះវាអាចមានការផ្លាស់ប្ដូរឬកែប្រែដោយសារជំងឺកូវីដ-19។
- បញ្ជាក់នូវព័ត៌មានការចុះឈ្មោះបោះឆ្នោតរបស់ថាត្រឹមត្រូវ មុនពេលចេញទៅកាន់ទីតាំងមណ្ឌលបោះឆ្នោតរបស់អ្នក។ ប្រសិនបើអ្នករស់នៅក្នុងរដ្ឋដែលអនុញ្ញាតឱ្យធ្វើការចុះឈ្មោះបោះឆ្នោតនៅទីតាំងនៃមណ្ឌលបោះឆ្នោតក្នុងអំឡុងពេលការបោះឆ្នោតមុនថ្ងៃកំណត់ ឬនៅថ្ងៃបោះឆ្នោត ចូរព្យាយាមបំពេញទម្រង់ការចុះឈ្មោះបោះឆ្នោតនៅមុនពេលមកដល់ទីតាំងនៃមណ្ឌលបោះឆ្នោត។
- ត្រូវប្រាកដថាអ្នកមានឯកសារចាំបាច់ទាំងអស់ដែលតម្រូវដោយរដ្ឋរបស់អ្នក ដូចជារូបថតអត្តសញ្ញាណដែលអាចទទួលយកបាន ដើម្បីចៀសវាងការពន្យាពេលនៅកន្លែងបោះឆ្នោត។
- ពិនិត្យមើលឡើងវិញឬបំពេញសន្លឹកឆ្នោតគម្រូនៅផ្ទះឱ្យហើយ ដើម្បីជួយពន្លឿនដល់ដំណើរការនៃការបោះឆ្នោតរបស់អ្នកនៅមណ្ឌលបោះឆ្នោត។ [សូមមើល https://ballotpedia.org/Sample_Ballot_Lookup សម្រាប់សន្លឹកឆ្នោតគម្រូ]។ សម្គាល់៖ ចំណុចដែលស្ថិតក្រោមផ្នែកទី 203 នៃច្បាប់ស្ដីពីសិទ្ធិបោះឆ្នោត ចែងថា ត្រូវផ្ដល់នូវសន្លឹកឆ្នោតគម្រូដែលបានបកប្រែជាភាសាទាំងនោះ។
- យកប៊ិចទឹកពណ៌ខ្មៅរបស់អ្នកមកជាមួយផង។
- យកប៊ិចឬឧបករណ៍ស្រដៀងគ្នាសម្រាប់ប្រើជាមួយនឹងម៉ាស៊ីនបោះឆ្នោតតម្រូវឱ្យប៉ះស្រ្ទីន។ សូមបញ្ជាក់ជាមួយមន្ត្រីបម្រើការនៅមណ្ឌលបោះឆ្នោត មុនពេលប្រើប្រាស់វា។

## ការអនុវត្តទម្លាប់ដើម្បីសុខភាព

- លាងដៃរបស់អ្នកមុនពេលចូលនិងបន្ទាប់ពីចាកចេញពីបន្ទប់បោះឆ្នោត។
- ពាក់ម៉ាស់។
- នៅពេលនៅមណ្ឌលបោះឆ្នោត ចូរប្រើទឹកលាង ដៃដែលមានជាតិអាលកុលយ៉ាងតិច 60% ឱ្យបានញឹកញាប់ ជាពិសេសក្រោយពេលប៉ះឬកាន់អ្វីដែលមនុស្សភាគច្រើនបានប៉ះពាល់ ដូចជាដៃទ្វារ ឬម៉ាស៊ីនបោះឆ្នោត។
- រក្សាគម្លាតយ៉ាងតិច 6 ហ្វីត (ប្រហែលប្រវែង 2 ដៃ) ពីអ្នកផ្សេងទៀត សូម្បីអ្នកនិងអ្នកផ្សេងទៀតមានពាក់ម៉ាស់ក៏ដោយ។
- ចូរកុំជូតសម្អាតឬបោសឧបករណ៍បោះឆ្នោតដោយខ្លួនអ្នកទេ។ ឧបករណ៍បោះឆ្នោតអេឡិចត្រូនិកអាចរងការខូចដោយអ្នកសម្អាតនិងសារធាតុគីមី។ ប្រសិនបើអ្នកប្រើទឹកលាងដៃដែលមានជាតិអាលកុលមុនពេលប៉ះឧបករណ៍បោះឆ្នោត អ្នកត្រូវប្រាកដថាដៃរបស់អ្នកត្រូវស្ងួតដើម្បីកុំឱ្យខូចដល់បរិក្ខារបោះឆ្នោត។ ចូរលាងដៃរបស់អ្នក ឬប្រើទឹកអាលកុលលាងដៃនៅបន្ទាប់ពីពេលអ្នកបានប្រើប្រាស់ឧបករណ៍បោះឆ្នោត។

www.advancingjustice-aajc.org/election2020